# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ៦ ខែធ្នូ ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Dec-2012, 09:50
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ការជូនដំណឹងរបស់ អៀង សារី អំពីការដកពាក្យសុំលះបង់សិទ្ធិមានវត្តមាន ក្នុងអំឡុងការធ្វើសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី អៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**ចម្លងជូន:**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ូរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **ធូ មុន្នី**

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសជ

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) សូម **ជូនដំណឹង** ដល់អង្គជំនុំជម្រះសាលាដំបូងអំពីការដកពាក្យសុំលះបង់សិទ្ធិមានវត្តមានក្នុងអំឡុងការធ្វើសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលរូបគាត់បានអនុវត្តកន្លងមក[1] និងសូម **ជូនដំណឹង** បន្ថែមទៀតអំពីគោលបំណងរបស់គាត់ក្នុងការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់គាត់ ក្នុងការទទួលបានការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធី*ដោយផ្ទាល់* ដោយមានវត្តមាននៅក្នុងបន្ទប់សវនាការក្នុងអំឡុងពេលការធ្វើសក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។ ប្រសិនបើលោក អៀង សារី សម្រេចចូលរួមក្នុងកិច្ចដំណើរការនីតិវិធី *ដោយប្រយោល* តាមរយៈមធ្យោបាយពីចម្ងាយដោយប្រើប្រាស់ឧបករណ៍សោតទស្សន៍នៅក្នុងបន្ទប់រង់ចាំរបស់គាត់ខាងក្រោមសវនាការនោះ គាត់នឹងលះបង់សិទ្ធិ និងស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងស្របគ្នាជាមួយនឹងការអនុវត្តដែលត្រូវបានបង្កើតឡើងចាប់តាំងពីការចាប់ផ្តើមកិច្ចដំណើរការនីតិវិធី។

## I. **សាវតារ**

1. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១២ លោក អៀង សារី ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យដោយសារតែភាពទន់ខ្សោយ និងហេវហត់អស់កម្លាំងរបស់គាត់[2]។ លោក អៀង សារី បានសម្រាកព្យាបាលនៅមន្ទីរពេទ្យអស់រយៈពេលជាងពីរខែ រហូតដល់ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទើបគាត់វិលត្រឡប់មកបន្ទប់ឃុំខ្លួនរបស់គាត់វិញនៅមន្ទីរឃុំឃាំងអ.វ.ត.ក[3]។

2. នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២ មេធាវីការពារក្តីបានផ្ញើលិខិតមួយទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់

---

[1] ពាក្យសុំលះបង់សិទ្ធិមានវត្តមានក្នុងកិច្ចដំណើរការសវនាការមានដែនកំណត់របស់លោក អៀង សារី ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E229។ ពាក្យសុំលះបង់សិទ្ធិមានវត្តមានក្នុងកិច្ចដំណើរការសវនាការមានដែនកំណត់របស់លោក អៀង សារី ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១២ ឯកសារ E237។ ពាក្យសុំលះបង់សិទ្ធិមានវត្តមានក្នុងកិច្ចដំណើរការសវនាការមានដែនកំណត់របស់លោក អៀង សារី ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១២ ឯកសារ E237/1។

[2] សារអេឡិចត្រូនិក ពីមន្ត្រីទំនាក់ទំនងជាន់ខ្ពស់ផ្នែកមន្ទីរឃុំឃាំង Claude Bouchard ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១២។ ប្រតិចារឹក ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E1/125.1 ទំព័រ ១២ (ភាសាអង់គ្លេស)។

[3] ការបញ្ជូន អៀង សារី មកកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក សម្រាប់សវនាការថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E239/2។

អង្គជំនុំជម្រះសាលាដំបូងដោយជម្រាបអង្គជំនុំជម្រះសាលាដំបូងថា លោក អៀង សារី នឹងយល់ព្រមលះបង់សិទ្ធិមានវត្តមានរបស់គាត់ក្នុងអំឡុងការធ្វើសក្ខីកម្មរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៨ រូប ដើម្បីអាចឲ្យដំណើរការជំនុំជម្រះក្ដីបន្តទៅមុខឲ្យបានឆាប់រហ័ស[4]។ មេធាវីការពារក្ដីបានបញ្ជាក់ថា លោក អៀង សារី បានយល់ព្រមលះបង់សិទ្ធិមានវត្តមានរបស់គាត់ផងដែរក្នុងអំឡុងពេលពិភាក្សាបញ្ហានីតិវិធីនានា ដូចជា សវនាការបដិសេធចម្លើយសាក្សី។ មេធាវីការពារក្ដីបានកត់សម្គាល់ថា នៅពេលដែលសមាជិកក្រុមមេធាវីការពារក្ដីបានជួបជាមួយលោក អៀង សារី នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១២ គាត់មានសភាពទន់ខ្សោយ និងមិនអាចផ្ដង់អារម្មណ៍បានក្នុងរយៈពេលលើសពី ១០ ឬ១៥នាទីបាន ដោយពុំមានអាការវិលមុខ និងភាន់ច្រឡំនោះឡើយ។ ដូច្នេះ មេធាវីការពារក្ដីបានទទូចឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណាឲ្យបានល្អិតល្អន់ឡើងវិញក្នុងការកំណត់កាលបរិច្ឆេទឡើងវិញ ចំពោះការធ្វើសក្ខីកម្មរបស់អ្នកជំនាញ Philip Short និង Elizabeth Becker ដែលអ្នកជំនាញទាំងពីរនេះត្រូវបានកំណត់មកធ្វើសក្ខីកម្ម នៅក្នុងខែតុលា ឆ្នាំ ២០១២។

3. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១២ ក.ស.ព បានដាក់ចម្លើយតបទៅនឹងការលះបង់សិទ្ធិនេះ ដែលនៅក្នុងចម្លើយតបនោះ ក.ស.ព បានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងស្នើឲ្យមេធាវីការពារក្ដីមានយោបល់ថាតើ លោក អៀង សារី មានបំណងចង់លះបង់សិទ្ធិក្នុងការមានវត្តមានរបស់គាត់ចំពោះសាក្សីបន្ថែមមួយចំនួនដែលភាគច្រើនពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្ម ឬយ៉ាងណា[5]។

4. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១២ មេធាវីការពារក្ដីបានដាក់ការជូនដំណឹងរបស់ អៀង សារី

---

[4] សូមមើល លិខិតពីមេធាវីការពារក្ដីផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង “ ការជូនដំណឹងពាក់ព័ន្ធនឹងសាក្សីនាពេលខាងមុខ និងពាក្យសុំលះបង់សិទ្ធិមានវត្តមានរបស់ អៀង សារី” ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២។ ពាក្យសុំលះបង់សិទ្ធិត្រូវបានដាក់ជូននៅថ្ងៃបន្ទាប់។ ពាក្យសុំលះបង់សិទ្ធិមានវត្តមានក្នុងកិច្ចដំណើរការសវនាការមានដែនកំណត់របស់លោក អៀង សារី ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E229។

[5] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការជូនដំណឹងពាក់ព័ន្ធនឹងសាក្សីនាពេលខាងមុខ និងពាក្យសុំលះបង់សិទ្ធិមានវត្តមានរបស់ អៀង សារី និងសំណើសុំឲ្យពិចារណាលើការកោះហៅសាក្សីសម្រាប់ដំណាក់កាលទីមួយបន្ថែមទៀត និងសាក្សីទីតាំងឧក្រិដ្ឋកម្មនៅក្នុងអំឡុងខែតុលា និងខែវិច្ឆិកា ចុះថ្ងៃទី ១៩ កញ្ញា ឆ្នាំ ២០១២ ឯកសារ E229/1។

ដោយបញ្ជាក់ថា គាត់នឹងមិនលះបង់សិទ្ធិរបស់គាត់ក្នុងការមានវត្តមានក្នុងអំឡុងពេលការធ្វើសក្ខីកម្មរបស់អ្នកជំនាញ Philip Short ឡើយ[6]។

5. នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ក្នុងខណៈដែលលោក អៀង សារី កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ វេជ្ជបណ្ឌិត លឹម ស៊ីវុតថា និង គី ប៊ូស្ស តំណាងឲ្យគណៈអភិបាលមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្នុងការត្រួតពិនិត្យសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំង អ.វ.ត.ក បានបង្ហាញវត្តមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្តល់ព័ត៌មានថ្មីៗដល់អង្គជំនុំជម្រះ និងភាគីនានា ទាក់ទិននឹងស្ថានភាពវេជ្ជសាស្ត្ររបស់លោក អៀង សារី[7]។ វេជ្ជបណ្ឌិត លឹម ស៊ីវុតថា បានផ្តល់សក្ខីកម្មថា នៅពេលនេះមិនទាន់មានការបញ្ជាក់ច្បាស់ថា លោក អៀង សារី ត្រូវនៅសម្រាកព្យាបាលរយៈពេលប៉ុន្មានទៀតឡើយ[8]។ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងបានស្តាប់សាក្សីនានា ទាក់ទិននឹងថាតើត្រូវស្តាប់ការធ្វើសក្ខីកម្មរបស់ Philip Short តាមកាលវិភាគដែលបានគ្រោងទុក ឬយ៉ាងណា។ ក.ស.ព ដោយមានការគាំទ្រពីដើមបណ្តឹងរដ្ឋប្បវេណី[9] បានបញ្ជាក់ថា ក.ស.ព មិនជំទាស់ទៅនឹងការផ្អាកការធ្វើសក្ខីកម្មរបស់ Philip Short[10] ឡើយ ដោយកត់សម្គាល់ថា មិនមានការខាតបង់ពេលវេលាជំនុំជម្រះក្តីឡើយ ដោយសារតែលោក អៀង សារី បានលះបង់សិទ្ធិរបស់គាត់ក្នុងការមានវត្តមានក្នុងសវនាការស្តាប់ចម្លើយសាក្សីមួយចំនួន និងសវនាការលើឯកសារនាពេលខាងមុខនេះ[11]។ ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ក៏បានគាំទ្រសំណើរបស់មេធាវីការពារក្តីផងដែរក្នុងការកំណត់កាលបរិច្ឆេទជាថ្មីឡើងវិញសម្រាប់ Philip

[6] ការជូនដំណឹងអំពីការមិនលះបង់សិទ្ធិដើម្បីមានវត្តមាននៅក្នុងដំណើរការនីតិវិធីនៅពេលលោក ហ្វីលីព សត (Philip Short) ធ្វើសក្ខីកម្ម ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E229/2។

[7] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E1/125.1។

[8] ដូចយោងខាងលើ ទំព័រ ៦៧។

[9] ដូចយោងខាងលើ ទំព័រ ៧៦-៧៧។

[10] ដូចយោងខាងលើ ទំព័រ ៧០។

[11] ដូចយោងខាងលើ ទំព័រ ៧២។

Short[12]។

6. នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ការធ្វើសក្ខីកម្មរបស់ Philip Short និង Elizabeth Becker នឹងត្រូវពន្យារពេល ដោយហេតុថា ភាគីទាំងអស់បានយល់ស្របថាការពន្យារពេលគឺជាការសមស្រប ហើយអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់សិទ្ធិរបស់លោក អៀង សារី ក្នុងការមានវត្តមានក្នុងអំឡុងពេលការធ្វើសក្ខីកម្មរបស់អ្នកជំនាញ។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា អង្គជំនុំជម្រះនឹងធ្វើប្រតិចារឹកនៃសវនាការថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ព្រមទាំងរបាយការណ៍វេជ្ជសាស្ត្ររបស់លោក អៀង សារី ជូនដល់សាស្ត្រាចារ្យ A. John Campbell ដើម្បីផ្តល់យោបល់[13]។

7. នៅថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១២ លោក អៀង សារី បានដាក់ពាក្យសុំលះបង់សិទ្ធិមានវត្តមានរបស់គាត់មួយទៀត ដោយលះបង់សិទ្ធិក្នុងការមានវត្តមានរបស់គាត់ក្នុងអំឡុងពេលការធ្វើសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៨ នាក់ ដែលបានស្នើឡើងដោយ ក.ស.ព[14]។

8. នៅថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយបញ្ជាក់អំពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះមានបំណងស្តាប់សក្ខីកម្ម ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន[15]។ អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យមេធាវីការពារក្តីបញ្ជាក់ថាតើលោក អៀង សារី នឹងយល់ព្រមលះបង់សិទ្ធិមានវត្តមានរបស់គាត់ក្នុងអំឡុងពេលការធ្វើសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះដែលមានបញ្ជាក់នៅក្នុងអនុស្សរណៈ[16]។

---

[12] ដូចយោងខាងលើ ទំព័រ ៨៦-៨៧។

[13] សេចក្តីណែនាំទៅភាគីក្រោយសវនាការថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E233 កថាខណ្ឌ ២។

[14] ពាក្យសុំលះបង់សិទ្ធិមានវត្តមានក្នុងកិច្ចដំណើរការសវនាការមានដែនកំណត់របស់លោក អៀង សារី ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១២ ឯកសារ E237។

[15] ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងអំឡុងសវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១២ ឯកសារ E236/1។

[16] ដូចយោងខាងលើ កថាខណ្ឌ ៥។

9. នៅថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១២ លោក អៀង សារី បានដាក់ពាក្យសុំលះបង់សិទ្ធិលើកទីបីក្នុងការមានវត្តមានរបស់គាត់ក្នុងអំឡុងពេលការធ្វើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤ នាក់ ដែលមានរាយនាមនៅក្នុងអនុស្សរណៈចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១២ របស់អង្គជំនុំជម្រះសាលាដំបូង[17]។ ដូច្នេះ នាំឲ្យចំនួនសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីសរុបដែលអាចធ្វើសក្ខីកម្មបាននៅក្នុងតុលាការដោយគ្មានវត្តមានរបស់លោក អៀង សារី កើនឡើងដល់ ៤០ នាក់។

10. នៅថ្ងៃទី ៥ និង ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ សាស្ត្រាចារ្យ Campbell បានពិនិត្យលោក អៀង សារី ហើយបានផ្តល់របាយការណ៍របស់គាត់ជូនដល់ភាគីនានានៅថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២[18]។ នៅក្នុងរបាយការណ៍នេះ សាស្ត្រាចារ្យ Campbell បានធ្វើសេចក្តីសន្និដ្ឋានថា លោក អៀង សារី មានសមត្ថភាពចូលរួមក្នុងសវនាការ ដោយបានផ្តល់អនុសាសន៍ឲ្យមានការកែប្រែបន្តិចបន្តួចប៉ុណ្ណោះក្នុងការថែទាំគាត់[19]។ នៅថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ សាស្ត្រាចារ្យ Campbell បានធ្វើសក្ខីកម្មនៅក្នុងតុលាការ[20]។ ការធ្វើសក្ខីកម្មរបស់គាត់ស៊ីសង្វាក់គ្នាជាមួយនឹងរបាយការណ៍របស់គាត់ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។

11. នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ មេធាវីការពារក្តីបានស្នើដោយផ្ទាល់មាត់ឲ្យអង្គជំនុំជម្រះសាលាដំបូងតែងតាំងអ្នកជំនាញបន្ថែមដើម្បីត្រួតពិនិត្យលោក អៀង សារី ដើម្បីវាយតម្លៃអំពីសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ[21]។ មេធាវីការពារក្តីបានបញ្ជាក់ថា លោក អៀង សារី នៅពេលនេះ មិនមានសម្បទាដើម្បីចូលរួមក្នុងសវនាការទេ ប៉ុន្តែថា ការជំនុំជម្រះក្តីអាចបន្តទៅមុខបានជាមួយនឹងសាក្សីនានាដែលលោក អៀង សារី បានលះបង់សិទ្ធិមានវត្តមានរបស់គាត់ចំពោះ

---

[17] ពាក្យសុំលះបង់សិទ្ធិមានវត្តមានក្នុងកិច្ចដំណើរការសវនាការមានដែនកំណត់របស់លោក អៀង សារី ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១២ ឯកសារ E237/1។

[18] របាយការណ៍អ្នកជំនាញស្តីអំពីលោក អៀង សារី ដែលត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E238) ចុះថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E238/4។

[19] ដូចយោងខាងលើ ទំព័រ ២-៦។

[20] ប្រតិចារឹក ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E1/142.1។

[21] ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E1/143.1 ទំព័រ ៧-១១ (ភាសាអង់គ្លេស)។

ការធ្វើសក្ខីកម្មរបស់សាក្សីទាំងនោះ ដោយសង្ឃឹមថាសុខភាពរបស់ លោក អៀង សារី អាចល្អប្រសើរឡើងវិញ[22]។ ក.ស.ព បានអះអាងថា សវនាការគួរតែបន្តដំណើរការទៅមុខ ដោយមានការចូលរួមរបស់លោក អៀង សារី ពីបន្ទប់រង់ចាំខាងក្រោមសវនាការ ហើយថា វាមិនចាំបាច់ឡើយក្នុងការស្តាប់សក្ខីកម្មពីអ្នកជំនាញបន្ថែមម្នាក់ទៀតនោះ[23]។ ដើមបណ្តឹងរដ្ឋប្បវេណីបានយល់ស្របជាមួយនឹង ក.ស.ព លើបញ្ហានេះ[24]។

12. នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួន ដោយយល់ឃើញថា លោក អៀង សារី មានសម្បទាក្នុងការចូលរួមសវនាការ ហើយបដិសេធសំណើរបស់មេធាវីការពារក្តីសុំឲ្យតែងតាំងអ្នកជំនាញផ្នែកវេជ្ជសាស្ត្របន្ថែមមួយរូបទៀតនោះ[25]។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថាតើ អង្គជំនុំជម្រះអាចបង្គាប់ឲ្យលោក អៀង សារី ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំខាងក្រោមសវនាការឬយ៉ាងណា ហើយអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា អង្គជំនុំជម្រះអាចធ្វើដូច្នេះបាន ដើម្បីជាផលប្រយោជន៍យុត្តិធម៌[26]។

## II. ច្បាប់ និង ឧទ្ធរណ៍

13. លោក អៀង សារី មានសិទ្ធិទទួលបានការការពារយ៉ាងពេញលេញដោយរដ្ឋធម្មនុញ្ញ[27] ក្នុងការចូលរួមនៅក្នុងកិច្ចដំណើរនីតិវិធី និងជួយការពារក្តីរបស់គាត់។ សិទ្ធិនេះត្រូវបានធានានៅក្នុងក្របខណ្ឌ

---

[22] ដូចយោងខាងលើ ទំព័រ ១១-១២។

[23] ដូចយោងខាងលើ ទំព័រ ២៥-៣០, ៣៦-៣៧។

[24] ដូចយោងខាងលើ ទំព័រ ៣៩-៤២។

[25] សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E238/9។

[26] ដូចយោងខាងលើ កថាខណ្ឌ ៣២-៣៤។

[27] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។ មាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

ច្បាប់នៅ អ.វ.ត.ក[28] និងដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”)[29] ដែលត្រូវតែគោរពដោយអនុលោមទៅតាមរដ្ឋធម្មនុញ្ញកម្ពុជា[30]។

14. សិទ្ធិរបស់លោក អៀង សារី ក្នុងការចូលរួមដោយផ្ទាល់នៅក្នុងកិច្ចដំណើរការនីតិវិធី រួមមានការធានាកម្រិតអប្បបរមាមួយចំនួន រួមទាំង សិទ្ធិទទួលបានការជំនុំជម្រះដោយមានវត្តមានរបស់គាត់ និងសិទ្ធិការពារខ្លួនដោយខ្លួនគាត់[31]។ អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា[32] ច្បាប់ស្តីពីការបង្កើត អ.វ.

---

ចែងថា៖ “ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖ ... (ឃ) ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន ...”។

[28] មាត្រា ៣៥ថ្មី(ឃ) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (គូសបញ្ជាក់បន្ថែម) ចែងថា៖

> ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។
>
> នៅក្នុងការចោទប្រកាន់មកលើខ្លួន *ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា* សមស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ ... ឃ/ *ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យ និងការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវីដែលជ្រើសរើសដោយខ្លួនឯង* ត្រូវបានប្រាប់អោយដឹងអំពីសិទ្ធិនេះ និងទទួលបាននូវជំនួយផ្នែកច្បាប់ ដោយឥតគិតថ្លៃ ប្រសិនបើជនជាប់ចោទ គ្មានលទ្ធភាពជួលដោយខ្លួនឯង ...។

វិធាន ៨១(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក (“វិធាន”) ចែងថា៖ “ការជំនុំជម្រះត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ លើកលែងតែមានបញ្ញត្តិផ្សេងចែងក្នុងវិធាននេះ”។ មាត្រា ៨១(៥) ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

> នៅពេលដែលមានមូលហេតុសុខភាព ឬ មូលហេតុធ្ងន់ធ្ងរដទៃទៀត ជនជាប់ចោទមិនអាចចូលរួមដោយផ្ទាល់ចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែ រូបកាយនិងស្មារតីសមស្រប អាចចូលរួមក្នុងដំណើរការនីតិវិធីបាន អង្គជំនុំជម្រះអាចបន្តនីតិវិធីដោយមិនមានវត្តមានរបស់ជនជាប់ចោទ ដោយមានការយល់ព្រមពីជនជាប់ចោទ ឬ នៅពេលដែលអវត្តមានរបស់ជនជាប់ចោទឈានដល់កម្រិតមួយ ដែលបណ្តាលឲ្យមានការពន្យាពេលយ៉ាងយូរ ហើយ នៅពេលដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវ អង្គជំនុំជម្រះបង្គាប់ថា ការចូលរួមរបស់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះត្រូវតែធ្វើឡើងតាមមធ្យោបាយសោតទស្សន៍សមស្រប។

[29] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ, មាត្រា ១៤(៣)(ឃ)។

[30] រដ្ឋធម្មនុញ្ញកម្ពុជា, មាត្រា ៣១។

[31] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៥ថ្មី(ឃ); កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ, មាត្រា ១៤(៣)(ឃ)។

ត.ក[33] វិធានផ្ទៃក្នុង[34] និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[35] លោក អៀង សារី មានសិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការក្នុងពេលជំនុំជម្រះរូបគាត់។

15. អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់សិទ្ធិជាសារវ័ន្តនេះនៅក្នុងកាលៈទេសៈជាច្រើន រួមទាំងការលើកពេលសវនាការមួយផ្នែក ឬទាំងស្រុង ចំនួន ១២ ថ្ងៃ នៃថ្ងៃកិច្ចដំណើរការនីតិវិធីសវនាការកន្លងមក[36]។ លោក អៀង សារី មានបំណងអនុវត្តសិទ្ធិនេះ ដូចដែលបានបញ្ជាក់នៅក្នុងលិខិតលះបង់សិទ្ធិមានវត្តមានរបស់ អៀង សារី ដែលត្រូវបានអនុវត្តនៅថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ និងមានភ្ជាប់មកជាមួយឯកសារនេះស្រាប់[37]។

16. អនុលោមតាមវិធាន ៨១(៥) អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យលោក អៀង សារី ចូលរួមកិច្ចដំណើរការនីតិវិធីតាមមធ្យោបាយសោតទស្សន៍បាន *តែ* នៅពេលដែល "អវត្តមានរបស់គាត់ឈានដល់កម្រិតមួយ ដែលបណ្តាលឲ្យមានការពន្យារពេលយ៉ាងយូរ *ហើយ* នៅពេលដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវ ..."[38]។

---

[32] រដ្ឋធម្មនុញ្ញកម្ពុជា, មាត្រា ៣១។

[33] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៥ថ្មី។

[34] វិធាន ៨១(១)។

[35] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ, មាត្រា ១៤(៣)(ឃ)។

[36] សេចក្តីសម្រេចស្តីពីសម្បទារបស់ជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារលេខ E238/9, កថាខណ្ឌ ៣២ *ដោយដកស្រង់ចេញពី* ការជំនុំជម្រះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១២, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១២, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១២, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១២, ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១២, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១២។ *សូមមើលផងដែរ ដូចខាងលើ*, កថាខណ្ឌ ១៩; ប្រតិចារឹក, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារលេខ E1/4.1, ទំព័រ ៦២ (ភាសាអង់គ្លេស)។

[37] *សូមមើល* ឧបសម្ព័ន្ធ។

[38] វិធាន ៨១(៥) (គូសបញ្ជាក់បន្ថែម)។

17. បើតាមការកំណត់ដោយវិធាន ៨១(៥) មុនពេលបង្គាប់ឲ្យលោក អៀង សារី ចូលរួមតាមមធ្យោបាយសោតទស្សន៍ មានលក្ខខណ្ឌតម្រូវចំនួនពីរដែលត្រូវបំពេញ៖ អវត្តមានរបស់លោក អៀង សារី ឈានដល់កម្រិតមួយដែលបណ្តាលឲ្យមានការពន្យារពេលយ៉ាងយូរ *ហើយ* ការបង្គាប់ឲ្យចូលរួមតាមមធ្យោបាយសោតទស្សន៍ត្រូវតែដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ អង្គជំនុំជម្រះអាចបង្គាប់ឲ្យលោក អៀង សារី ចូលរួមពីបន្ទប់រង់ចាំ "នៅពេលដែលវត្តមាន[របស់លោក អៀង សារី] នៅក្នុងបន្ទប់សវនាការ អាចនឹងមិនស្របទៅនឹងស្ថានភាពផ្នែកវេជ្ជសាស្ត្ររបស់គាត់ និង/ឬទៅនឹងការប្រព្រឹត្តទៅឲ្យបានឆាប់រហ័សនៃការជំនុំជម្រះ"[39]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់ថា ការសម្រេចបែបនេះ "មិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការសម្រេចមានវត្តមាននៅក្នុងបន្ទប់សវនាការក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះគ្រប់ពេលវេលានោះទេ ..."[40]។

18. ដោយសារថាលោក អៀង សារី នឹងមានវត្តមានក្នុងបន្ទប់សវនាការនោះ នឹងពុំមានការពន្យារពេលច្រើននៃកិច្ចដំណើរការនីតិវិធីទេ។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់ពិចារណាថា តើប្រយោជន៍នៃយុត្តិធម៌តម្រូវឲ្យគាត់ចូលរួមពីបន្ទប់រង់ចាំនោះទេ។ ការរំខានបន្តិចបន្តួច ឬការពន្យារពេលកិច្ចដំណើរការនីតិវិធីប្រចាំថ្ងៃ មិនមែនជាមូលហេតុដើម្បីបដិសេធសិទ្ធិរបស់លោក អៀង សារី ក្នុងការចូលរួមដោយផ្ទាល់ក្នុងការជំនុំជម្រះក្តីនោះទេ។

19. លោក អៀង សារី នៅតែទាមទារសុំប្រើប្រាស់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការ។ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា គាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី និងចូលរួមបានយ៉ាងពេញលេញក្នុងការការពារខ្លួនដោយផ្ទាល់ហើយនោះ[41] អង្គជំនុំជម្រះសាលាដំបូង*ត្រូវតែ* គោរពដល់លោក អៀង សារី ក្នុងការអនុវត្តសិទ្ធិរបស់គាត់។

---

[39] សេចក្តីសម្រេចស្តីពីសម្បទារបស់ជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារលេខ E238/9, កថាខណ្ឌ ៣៤។

[40] *ដូចខាងលើ*។

[41] *ដូចខាងលើ*, កថាខណ្ឌ ២៦។

20. ដោយផ្អែកលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង (ធ្វើឡើងដោយផ្អែកលើរបាយការណ៍របស់សាស្ត្រាចារ្យ Campbell) ដែលថា លោក អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះនោះ លោក អៀង សារី ពុំគួរមានបញ្ហាក្នុងការតាមដានកិច្ចដំណើរការនីតិវិធីនៅតុលាការទេដរាបណាគាត់នៅពាក់ប្រដាប់ទប់ក និងដេកត្រង់ខ្លួននោះ។ ប្រសិនបើមានកាលៈទេសៈផ្សេងកើតឡើង ពោលគឺ ប្រសិនបើ លោក អៀង សារី (ទោះបីគាត់មានបំណងចង់ចូលរួមឲ្យបានពេញលេញគ្រប់ពេលក៏ដោយ) មិនអាចតាមដានកិច្ចដំណើរការនីតិវិធីបាន គួរមានការធានាថា ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងគួរតែប្រកាសឲ្យដឹងពីបញ្ហានេះ តាមរយៈការសង្កេតទៅលើរូបគាត់។ នៅក្នុងបន្ទប់រង់ចាំ សហមេធាវីមិនអាចឃើញលោក អៀង សារី ទេ ហេតុនេះពួកគេពុំមានឱកាសក្នុងការអនុវត្តការងាររបស់ខ្លួនយ៉ាងយកចិត្តទុកដាក់ ក្នុងការការពារសិទ្ធិរបស់លោក អៀង សារី ក្នុងការចូលរួមក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនោះទេ។ ធ្ងន់ធ្ងរជាងនេះទៀត ការដាក់លោក អៀង សារី ក្នុងបន្ទប់រង់ចាំអង្គជំនុំជម្រះសាលាដំបូង អាចមានបំណងលាក់បាំងមិនចង់ឃើញពីស្ថានភាពពិតប្រាកដរបស់លោក អៀង សារី។ ការប៉ះពាល់ធ្ងន់ធ្ងរដោយសារសកម្មភាពរបស់អង្គជំនុំជម្រះសាលាដំបូងបែបនេះ នឹងនាំឲ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។

21. កាលពីមុន អង្គជំនុំជម្រះសាលាដំបូងធ្លាប់តម្រូវឲ្យលោក អៀង សារី ត្រូវបានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ ទោះបីនៅពេលគាត់ជ្រើសរើសចូលរួមពីបន្ទប់រង់ចាំក៏ដោយ ដើម្បី "បង្ហាញដល់ភាគី និងសាធារណជនថា ជនជាប់ចោទពិតជាបានស្តាប់ពីបទចោទមកលើខ្លួនមែន"[42]។ នៅ

---

[42] នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្នុងពេលធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០១ លោក អៀង សារី បានស្នើសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំ ដោយសារគាត់ឈឺខ្នង។ ប្រតិចារឹក, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E1/13.1, ទំព័រ ៣៦ (ភាសាអង់គ្លេស)។ សំណើនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងបដិសេធ ដោយសារចាំបាច់ "ដើម្បីបង្ហាញដល់ភាគី និងសាធារណជនថា ជនជាប់ចោទពិតជាបានស្តាប់ពីបទចោទមកលើខ្លួនមែន"។ *ដូចខាងលើ*។ នៅថ្ងៃបន្ទាប់ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំចូលរួមការជំនុំជម្រះពីបន្ទប់រង់ចាំ។ ប្រតិចារឹក, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E1/14.1, ទំព័រ ៨ (ភាសាអង់គ្លេស)។ មេធាវីការពារក្តីបានប្តឹងសាទុក្ខទៅនឹងសេចក្តីសម្រេចនេះដែលបង្ខំលោក អៀង សារី ឲ្យស្ថិតនៅក្នុងបន្ទប់សវនាការ តែបណ្តឹងសាទុក្ខត្រូវបានសន្និដ្ឋានថា មិនអាចទទួលយកបាន។ *សូមមើល*

ពេលនេះ វានឹង *ពុំ* មែនជាប្រយោជន៍នៃយុត្តិធម៌ទេ ដែលបង្គាប់ឲ្យលោក អៀង សារី ចូលរួមសវនាការពីចម្ងាយនោះ ជាពិសេសដោយសារ អង្គជំនុំជម្រះសាលាដំបូងមិនអាចផ្ទៀងផ្ទាត់ថា តើលោក អៀង សារី ពិតជាកំពុងតាមដានកិច្ចដំណើរការនីតិវិធី និងពិតជាកំពុងចូលរួមការពារខ្លួនដោយខ្លួនឯងបានទេ ប្រសិនបើគាត់ត្រូវស្ថិតក្នុងបន្ទប់រង់ចាំនោះ[43]។

22. អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងនូវលទ្ធភាពដែលថា អង្គជំនុំជម្រះមិនអាចអនុញ្ញាតឲ្យប្រើគ្រែពេទ្យក្នុងបន្ទប់សវនាការទេ[44]។ ដោយពិចារណាឃើញថា លោក អៀង សារី បានជ្រើសរើសអនុវត្តសិទ្ធិរបស់គាត់ក្នុងការមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនោះ អង្គជំនុំជម្រះគួរតែ

---

បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបដិសេធសិទ្ធិសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសាលសវនាការ ក្នុងអំឡុងពេលជំនុំជម្រះក្តី និងបានបដិសេធសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញ ក្នុងការទទួលបានការជួយការពារក្តីរបស់គាត់ដោយខ្លួនគាត់, ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២, ឯកសារលេខ E130/4/1; សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២, ឯកសារលេខ E130/4/3។

[43] ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានកត់សម្គាល់រួចមកហើយគឺថា ក្នុងការសម្រេចពីសម្បទាក្នុងការចូលរួមសវនាការ អង្គជំនុំជម្រះសាលាដំបូងអាចពឹងផ្អែកលើការសង្កេតរបស់ខ្លួនចំពោះជនជាប់ចោទ ក្នុងពេលកំពុងដំណើរការនីតិវិធី។ សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E115/3, កថាខណ្ឌ ១៨។ វាជាការសំខាន់ដែលថា អង្គជំនុំជម្រះសាលាដំបូងត្រូវសង្កេតទៅលើលោក អៀង សារី ដោយសារ ទោះបីអង្គជំនុំជម្រះបានសម្រេចថា នៅពេលនេះលោក អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការក៏ដោយ តែដោយសារគាត់មានសុខភាពចុះទ្រុឌទ្រោមនោះ គាត់អាចនឹងពុំមានសម្បទាគ្រប់គ្រាន់ទេ។ ការសង្កេតរបស់អង្គជំនុំជម្រះសាលាដំបូងនឹងជួយក្នុងការសម្រេចពីសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការនាពេលអនាគត។

[44] នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការនោះ អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា សាស្ត្រាចារ្យ Campbell មិនបាន "រួមបញ្ចូលការផ្តល់គ្រែពេទ្យនៅក្នុងបន្ទប់សវនាការ ទៅក្នុងបញ្ជីរាយឈ្មោះវិធានការដែលត្រូវបានយល់ឃើញថា ដើម្បីលើកម្ពស់សុខុមាលភាពរបស់ជនជាប់ចោទ ឬដើម្បីធ្វើឲ្យសមស្របខាងផ្នែកវេជ្ជសាស្ត្រឡើយ"។ សេចក្តីសម្រេចស្តីពីសម្បទារបស់ជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារលេខ E238/9, កថាខណ្ឌ ៣៣។

អនុញ្ញាតរៀបចំឲ្យមានកន្លែងសម្រាកសមរម្យសម្រាប់វត្តមានរបស់គាត់[45]។ វាជាការរំលោភដោយមិនអាចប្រកែកបានទៅលើសិទ្ធិរបស់លោក អៀង សារី ក្នុងការចូលរួមការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលអង្គជំនុំជម្រះបដិសេធសិទ្ធិរបស់គាត់ក្នុងការមានវត្តមានក្នុងបន្ទប់សវនាការដោយសារតែអង្គជំនុំជម្រះសាលាដំបូងយល់ថា វាមិនសមស្របដែលត្រូវយកគ្រែពេទ្យមកចូលក្នុងបន្ទប់សវនាការនោះ។

**អាស្រ័យហេតុនេះ** សម្រាប់សំអាងហេតុនានាដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូម**ជូនដំណឹង**ដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តាជ្រាបថា លោក អៀង សារី នឹងដកការលះបង់សិទ្ធិមានវត្តមានក្នុងអំឡុងពេលសក្ខីកម្មរបស់សាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណី និងមានបំណងមានវត្តមាននៅក្នុងបន្ទប់សវនាការក្នុងពេលមានសក្ខីកម្មទាំងអស់។

សូមលោក លោកស្រីចៅក្រម មេត្តាទទួលយកសេចក្តីជូនដំណឹងដោយគោរព។

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីការពារក្តី លោក អៀង សារី

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា **ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១២**

[45] អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានផ្តល់កន្លែងសម្រាកសមរម្យ ដើម្បីឲ្យលោក អៀង សារី អាចមានវត្តមានក្នុងបន្ទប់សវនាការបាន ដូចជារៀបចំកៅអីទម្រេតខ្លួន និងដាក់កន្លែងអង្គុយរបស់លោក អៀង សារី នៅជ្រុងមួយនៃបន្ទប់សវនាការដែលនៅជិតបន្ទប់ទឹកបំផុត។ *សូមមើលឧទាហរណ៍* សារអេឡិចត្រូនិករបស់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនមេធាវីការពារក្តី “ការអនុវត្តតាមរបាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ/កម្មវត្ថុ “កៅអីទម្រេតខ្លួន” សម្រាប់ អៀង សារី” ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១។